# ឱកាសការងារជាមួយ សាមិក ភីអិលស៊ី

## អំពីសាមិក ភីអិលស៊ី

សាមិក ភីអិលស៊ី ជាស្ថាប័នមីក្រូហិរញ្ញវត្ថុដ៏ល្បីល្បាញមួយនៅក្នុងប្រទេសកម្ពុជា ដែលបានទទួលអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងចុះបញ្ជីជាក្រុមហ៊ុនឯកជនទទួលខុសត្រូវ មានកម្រិត ជាមួយក្រសួងពាណិជ្ជកម្មលើបញ្ជីការលេខ Co. ៧៨៥៧/KH/២០០៥ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០៥។ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ សាមិក ភីអិលស៊ី បានផ្លាស់ប្តូរប្រភេទក្រុមហ៊ុន ពីក្រុមហ៊ុនឯកជន ទទួលខុសត្រូវមានកម្រិត ទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលទទួលបានការអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម និងធនាគារជាតិនៃកម្ពុជា។

អនុលោមតាមកំណើនឥណទាន និងតំបន់ប្រតិបត្តិការរបស់ក្រុមហ៊ុន សាមិក ភីអិលស៊ី សូមធ្វើការប្រកាសជ្រើសរើសបេក្ខជន ដែលមានគុណវុឌ្ឍន៍ តួនាទី និងលក្ខណៈសម្បត្តិ ដូចខាងក្រោម ៖

| មុខតំណែង | ចំនួន | ទីតាំងបម្រើការងារ | ផុតកំណត់ |
|---|---|---|---|
| មន្ត្រីឥណទាន | ១១ នាក់ | ខេត្តកណ្តាល (ស្រុកអង្គស្នួល), ខេត្តតាកែវ (ស្រុកត្រាំកក់ និងស្រុកត្រាំខ្នា), ខេត្តសៀមរាប(ស្រុកពួក), ខេត្តកំពង់ធំ(ស្រុកបារាយ៍), ខេត្តកំពត(ស្រុកឈូក, បន្ទាយមាស និងស្រុកកំពង់ត្រាច),ខេត្តព្រះសីហនុ(ក្រុងព្រះសីហនុ, ស្ទឹងហាវ និងស្រុកព្រៃនប់) និងខេត្តកំពង់ស្ពឺ | ២០ មីនា ២០១៧ |
| មន្ត្រីឥណទានស្ម័គ្រចិត្ត | ០៥ នាក់ | ភ្នំពេញ (សែនសុខ), កណ្តាល (ស្អាង), តាកែវ (ត្រាំកក់), កំពត (ក្រុងកំពត, កំពង់ត្រាច) | |

## តួនាទី និងភារកិច្ចទទួលខុសត្រូវ៖

- រៀបចំ និងអនុវត្តន៍ផែនការសកម្មភាពដោយអនុលោមតាមគោលការណ៍ និងនីតិវិធីឥណទានរបស់សាមិកដែលបានដាក់ជូនពីថ្នាក់លើ។
- រៀបចំផែនការការងារប្រចាំសប្តាហ៍ និងប្រចាំខែ ឲ្យបានទៀងទាត់ តាមពេលវេលាសមរម្យ រួមទាំងផែនការប្រមូលប្រាក់ ទំលាក់ទុនឥណទានពីប្រធានសាខាស្រុក។
- ជួយសម្របសម្រួលការងារប្រតិបត្តិការជាមួយប្រធានសាខាស្រុក ក្នុងការរៀបចំផែនការចលនាសាច់ប្រាក់ប្រចាំត្រីមាស និងប្រចាំឆ្នាំ។
- ផ្សព្វផ្សាយអំពីផលិតផល និងសេវាកម្មរបស់សាមិក ដល់អតិថិជនគោលដៅក្នុងតំបន់មានសក្តានុពល និង គ្រប់គ្រងរក្សាផលប័ត្រកម្ចី និងចំនួនអតិថិជនប្រកបដោយប្រសិទ្ធិភាពខ្ពស់។
- មានទំនាក់ទំនងល្អ ជាមួយអាជ្ញាធរមូលដ្ឋាន ដូចជា ប្រធានភូមិ មេឃុំ ប្រធាននគរបាលនិងប្រតិបត្តិករឥណទានដទៃទៀតក្នុងតំបន់ប្រតិបត្តិការ។
- ទទួលការងារពាក់ព័ន្ធចាត់តាំងដោយប្រធានសាខាស្រុក

## លក្ខណសម្បត្តិរបស់បេក្ខជន៖

- ថ្នាក់បរិញ្ញាបត្រ / បរិញ្ញាបត្ររង ជំនាញ ធនាគារ និងហិរញ្ញវត្ថុ ទីផ្សារ ឬប្រហាក់ប្រហែល *(យ៉ាងតិចត្រឹមបាក់ឌុប)*
- សិស្សនិសិត្សដែលមិនមានបទពិសោធន៍ក៏ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យ
- អាចនិយាយ និងប្រើប្រាស់ភាសាអង់គ្លេសបានកាន់តែល្អ
- មានអត្តចរិកស្លូតបូត សុភាពរាបសា និងមានទំនាក់ទំនងល្អ
- តស៊ូព្យាយាមក្នុងការងារ ពិសេសចេះប្រឈមនឹងសំពាធការងារ
- មានចំណេះដឹងផ្នែកប្រព័ន្ធគ្រប់គ្រងគណនី
- ខិតខំធ្វើការងារ និងចេះលើកទឹកចិត្តខ្លួនឯង
- មានឆន្ទៈខ្ពស់ក្នុងការទទួលយកការងារថ្មីៗ និងមានភាពស្មោះត្រង់

## ព័ត៌មានទំនាក់ទំនងដាក់ពាក្យ៖

បេក្ខជនដែលមានចំណាប់អារម្មណ៍ អាចដាក់ពាក្យសុំចូលធ្វើការដោយភ្ជាប់មកជាមួយនូវ ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ X ៦ ចំនួន ០១ ច្បាប់ នៅសាខាណាមួយនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសាមិក ដែលនៅជិតលោកអ្នក ឬទំនាក់ទំនងដាក់ពាក្យតាមរយៈ៖

- **ទូរស័ព្ទលេខ៖** ០១០ ៧៨៩ ៩៦៧/០៧៧ ៧៦៧ ៨៥៧
- **អ៊ីម៉ែល៖** ro-tola@samic.com.kh
- **វេបសាយ៖** www.samic.com.kh
- **អាសយដ្ឋាន៖** ផ្ទះលេខ #C៥៧-៦១, ផ្លូវ ធៀវហ្វ៊ីលណេស, សង្កាត់ទឹកថ្លា, ខណ្ឌសែនសុខ, រាជធានីភ្នំពេញ